ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងអភិវឌ្ឍន៍ជនបទ

# គោលការណ៍ណែនាំ

## ស្ដីពី

## ការជំរុញឲ្យវិស័យឯកជនចូលរួមក្នុងការផ្ដល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ




ខែមិថុនា ឆ្នាំ ២០២៣

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ណែនាំ

## ស្តីពី

# ការជំរុញឲ្យវិស័យឯកជនចូលរួមក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ




**ខែមិថុនា ឆ្នាំ ២០២៣**

# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដើម្បីជំរុញឲ្យវិស័យឯកជនចូលរួមក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅតំបន់ជនបទ។ ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំផែនការយុទ្ធសាស្ត្រជាតិ (NSP) ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅតំបន់ជនបទ ឆ្នាំ ២០១៤-២០២៥ ហើយត្រូវបានអនុវត្តតាមរយៈផែនការសកម្មភាពជាតិ (NAPs) ស្តីពីការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ ជំហានទី ១ និងជំហានទី ២ ឆ្នាំ ២០១៤-២០១៨ និងឆ្នាំ ២០១៩-២០២៣។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅប្រទេសកម្ពុជា (CSDG) ទី ៦ បានចែងថា៖ **“ធានាឲ្យមានទឹកស្អាត និងអនាម័យ និងការគ្រប់គ្រងប្រកបដោយនិរន្តរភាពសម្រាប់ប្រជាពលរដ្ឋគ្រប់គ្នា”** បានព្យាយាមសម្រេចឲ្យបាននូវអត្រាគ្របដណ្តប់សេវាកម្មគ្រប់គ្រងទឹកស្អាតប្រកបដោយសុវត្ថិភាព ១០០% សេវាកម្មភាពស្អាត នៃការគ្រប់គ្រងប្រកបដោយសុវត្ថិភាព ៥០% និងសេវាអនាម័យនៅតំបន់ជនបទ ១០០% នៅឆ្នាំ ២០៣០។

ដើម្បីសម្រេចបាននូវគោលដៅដ៏មហិមានេះ ក្រសួងអភិវឌ្ឍន៍ជនបទបាននិងកំពុងបន្តលើកទឹកចិត្តដល់វិស័យឯកជនឲ្យចូលរួមចំណែកទៅតាមលទ្ធភាព ទំហំការងារ និងគោលបំណងផ្សេងៗ ដូចជា ប្រភពផ្តល់ហិរញ្ញប្បទាន និង/ឬជួយជំរុញប្រសិទ្ធផលក្នុងការផ្តល់សេវាកម្ម កាត់បន្ថយការចំណាយ ចូលរួមចំណែកដល់និរន្តភាពយូរអង្វែងក្នុងការផ្លាស់ប្តូរ និងការចែករំលែកបច្ចេកវិទ្យា។ ដោយទទួលស្គាល់ពីតួនាទី និងការចូលរួមចំណែកដ៏សំខាន់របស់វិស័យឯកជនក្នុងការអភិវឌ្ឍវិស័យនេះ ក្រសួងអភិវឌ្ឍន៍ជនបទបន្តពង្រឹង និងពង្រីកបន្ថែមនូវបរិយាកាសអំណោយផលដល់ការចូលរួមរបស់វិស័យឯកជន ក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅតំបន់ជនបទ។

គោលការណ៍ណែនាំ ស្តីពីការជំរុញឲ្យវិស័យឯកជនចូលរួមក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទត្រូវបានបង្កើត និងរៀបចំឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទ។ គោលការណ៍ណែនាំនេះត្រូវបានចាត់ទុកថា ជាជំហានដំបូងដើម្បីជួយដល់ក្រសួង ក៏ដូចជាមន្ទីរអភិវឌ្ឍន៍ជនបទខេត្តនានា ក្នុងការលើកទឹកចិត្តដល់វិស័យឯកជនឲ្យចូលរួមចំណែកផ្តល់សេវាកម្ម និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដែលទាក់ទាញការវិនិយោគ និងកៀរគរធនធានពីវិស័យឯកជន និងដើម្បីបម្រើផលប្រយោជន៍សង្គម និងប្រជាជនក្នុងការសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។ គោលការណ៍ណែនាំនេះត្រូវបានបង្កើត និងរៀបចំឡើងដោយផ្អែកទៅលើការប្រមែប្រមូលនូវបទពិសោធន៍ល្អៗ នៃការចូលរួមរបស់វិស័យឯកជនរយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ និងមានការពិគ្រោះយោបល់ជាមួយអ្នកជំនាញសំខាន់ៗពីវិស័យសាធារណៈ និងឯកជន ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាផងដែរ។

ក្នុងនាមក្រសួងអភិវឌ្ឍន៍ជនបទ និងរូបខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមក្នុងការបង្កើត និងរៀបចំគោលការណ៍ណែនាំ ស្តីពីការជំរុញឲ្យវិស័យឯកជនចូលរួមក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនេះ។

ថ្ងៃសុក្រ ១៣ រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០២៣

**រដ្ឋមន្ត្រី**

បណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន**

# សេចក្តីថ្លែងអំណរគុណ

គោលការណ៍ណែនាំ ស្តីពីការជំរុញឲ្យវិស័យឯកជនចូលរួមក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ត្រូវបានបង្កើត និងរៀបចំឡើងដោយក្រុមការងារបច្ចេកទេសរបស់នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ ដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយអង្គការ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានា។

ក្នុងនាមក្រុមការងារបច្ចេកទេសរបស់នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ** ឯកឧត្តម **អ៊ុក ពញ្ញា** រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ ឯកឧត្តម **ទ្រី មេង** រដ្ឋលេខាធិការ ឯកឧត្តមបណ្ឌិត **នួន ដាញ៉ិល** រដ្ឋលេខាធិការ ឯកឧត្តម **យឹម ឌុង** រដ្ឋលេខាធិការ ឯកឧត្តម **នួន ពេជ្រនិមិត្ត** អនុរដ្ឋលេខាធិការ ឯកឧត្តម **អ៊ឹង វណ្ណា** អនុរដ្ឋលេខាធិការ និង ឯកឧត្តម **ជ្រាយ ម៉ុម** អគ្គនាយកបច្ចេកទេស ដែលបានគាំទ្រ និងណែនាំដ៏ខ្ពង់ខ្ពស់ដល់ការបង្កើត និងរៀបចំគោលការណ៍ណែនាំ ស្តីពីការជំរុញឲ្យវិស័យឯកជនចូលរួមក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនេះ។

ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គការ ដៃគូអភិវឌ្ឍន៍ និងគ្រប់ភាគីពាក់ព័ន្ធនានា ដែលបានផ្តល់មតិ យោបល់ក្នុងការបង្កើត រៀបចំ និងចូលរួមផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីការជំរុញឲ្យវិស័យឯកជនចូលរួមក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនេះ។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ២០២៣

**ប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ**

**ស្រ៊ុន ពុទ្ធី**

# អក្សរកាត់

| | | |
|---|---|---|
| ADB | Asian Development Bank | : ធនាគារអភិវឌ្ឍន៍អាស៊ី |
| DRWS | Department of Rural Water Supply | : នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ |
| ILO | International Labour Organization | : អង្គការពលកម្មអន្តរជាតិ |
| MRD | Ministry of Rural Development | : ក្រសួងអភិវឌ្ឍន៍ជនបទ |
| NAP | National Action Plan | : ផែនការសកម្មភាពជាតិ |
| NGOs | Non-Governmental Organizations | : អង្គការមិនមែនរដ្ឋាភិបាល |
| NSP | National Strategic Plan | : ផែនការយុទ្ធសាស្ត្រជាតិ |
| OECD | The Organization for Economic Co-operation and Development | : អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ |
| PDRD | Provincial Department of Rural Development | : មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត |
| PS | Private Sector | : វិស័យឯកជន |
| RWSSH | Rural Water Supply, Sanitation and Hygiene | : ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ |
| SDG | Sustainable Development Goals | : គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SME | Small and Medium-sized Enterprise | : សហគ្រាសធុនតូច និងមធ្យម |
| TRWSS | Third Rural Water Supply and Sanitation Services | : សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទដំណាក់កាលទី ៣ |
| WASH | Water Sanitation and Hygiene | : ទឹកស្អាត និងអនាម័យ |

# មាតិកា


**បុព្វកថា** .......... 1

**សេចក្ដីថ្លែងអំណរគុណ** .......... 2

**អក្សរកាត់** .......... 3

**១. សេចក្ដីផ្ដើម** .......... 5

**២. គោលបំណង នៃគោលការណ៍ណែនាំ** .......... 6

**៣. វិសាលភាព នៃគោលការណ៍ណែនាំ** .......... 7

**៤. គោលការណ៍ជំរុញឲ្យវិស័យឯកជនចូលរួមក្នុងការផ្ដល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ** .......... 8

៤.១ គោលការណ៍ទី ១៖ ធ្វើឲ្យមាននិរន្តរភាពហិរញ្ញវត្ថុ នៃគម្រោង/កម្មវិធីវិនិយោគវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ .......... 8

៤.២ គោលការណ៍ទី ២៖ ជំរុញឲ្យមានបរិយាកាសអំណោយផលដល់ការចូលរួមរបស់វិស័យឯកជន .......... 9

៤.៣ គោលការណ៍ទី ៣៖ បង្កើតបរិយាកាសប្រកួតប្រជែងដោយត្រឹមត្រូវ និងស្មើភាពគ្នា .......... 10

៤.៤ គោលការណ៍ទី ៤៖ ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ .......... 11

៤.៥ គោលការណ៍ទី ៥៖ ប្រាស្រ័យទាក់ទងរវាងអ្នកអនុវត្តការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ .......... 11

៤.៦ គោលការណ៍ទី ៦៖ បញ្ចេញព័ត៌មានដែលពាក់ព័ន្ធទៅនឹងគម្រោង/កម្មវិធី .......... 12

៤.៧ គោលការណ៍ទី ៧៖ រៀបចំកិច្ចសន្យាដែលត្រូវធ្វើឡើងដោយត្រឹមត្រូវ គ្មានការរើសអើង និងមានតម្លាភាព .......... 13

៤.៨ គោលការណ៍ទី ៨៖ រៀបចំកិច្ចសន្យាដោយផ្អែកទៅលើការអនុវត្ត/លទ្ធផលការងារ .......... 14

៤.៩ គោលការណ៍ទី ៩៖ អនុញ្ញាតឲ្យមានការចរចាកែសម្រួលលក្ខខណ្ឌឡើងវិញ ដោយឈរលើគោលការណ៍ត្រឹមត្រូវ ស្មោះត្រង់ តម្លាភាព និងគ្មានការរើសអើង .......... 15

៤.១០ គោលការណ៍ទី ១០៖ ប្រើប្រាស់យន្តការដោះស្រាយវិវាទដែលមានស្រាប់ .......... 16

៤.១១ គោលការណ៍ទី ១១៖ ជំរុញឲ្យការធ្វើធុរកិច្ចប្រកបដោយការទទួលខុសត្រូវ .......... 16

៤.១២ គោលការណ៍ទី ១២៖ យល់ដឹង និងទទួលខុសត្រូវសម្រាប់ផលវិបាកនានាដល់សង្គម .......... 17

**ឯកសារយោង** .......... 19

## ១. សេចក្តីផ្តើម

កង្វះទឹកស្អាត ភាពស្អាត និងអនាម័យ គឺជាបញ្ហាប្រឈមដ៏ធំមួយ ដោយសារតែនៅទូទាំងពិភពលោក មនុស្សជាងមួយពាន់លាននាក់នៅពុំទាន់មានលទ្ធភាពទទួលបានទឹកស្អាតផឹក ហើយប្រជាពលរដ្ឋ ២,៦ ពាន់លាននាក់ទៀតកំពុងខ្វះសេវាកម្មអនាម័យជាមូលដ្ឋាននៅឡើយ។ កាលពីគ្រាដំបូង នៃការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ធនាគារពិភពលោក (Hutton and Varughese, ២០១៦) បានបោះពុម្ពផ្សាយអំពីការសិក្សាចំណាយមួយ ដោយរួមបញ្ចូលគោលដៅ ៦.១ និង ៦.២។ ការសិក្សាបានប៉ាន់ប្រមាណថា ដើម្បីរ៉ាប់រងការចំណាយក្នុងការពង្រីកលទ្ធភាពទទួលបានរបស់ប្រជាពលរដ្ឋដែលពុំទទួលបានសេវា ប្រទេសជាច្រើនត្រូវការទឹកប្រាក់ ១១៤ ពាន់លានដុល្លារអាមេរិកជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០៣០ ដើម្បីសម្រេចបានគោលដៅទឹកស្អាត ភាពស្អាត និងអនាម័យជាសកល (គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គោលដៅ ៦.១ និង ៦.២)។ ការសិក្សានេះរួមបញ្ចូលប្រទេសចំណូលទាប និងចំណូលមធ្យមចំនួន ១៤០ ព្រមទាំងប្រទេសអភិវឌ្ឍន៍ជឿនលឿនដែលពុំទាន់សម្រេចបានលទ្ធភាពទទួលបានសេវាកម្មអនាម័យមូលដ្ឋានជាសកលនៅឡើយ។

ការសិក្សានេះក៏បានប៉ាន់ប្រមាណផងដែរថា ជារៀងរាល់ឆ្នាំរដ្ឋត្រូវចំណាយទឹកប្រាក់ ១៩,៥ ពាន់លានដុល្លាអាមេរិកចំពោះអនាម័យជាមូលដ្ឋាន និង ៤៩,៣ ពាន់លានដុល្លារអាមេរិកបន្ថែមទៀតសម្រាប់អនាម័យប្រកបដោយសុវត្ថិភាព ដែលសរុបជាទឹកប្រាក់គឺ ៦៨,៨ ពាន់លានដុល្លាអាមេរិកក្នុងមួយឆ្នាំ។ ដូច្នេះ ៦០% នៃចំណាយសរុបប្រចាំឆ្នាំ គឺផ្តោតទៅលើអនាម័យ ក្នុងន័យសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ៦.១ និង ៦.២ ។ ប្រសិនបើ រដ្ឋត្រូវការចំនួនទឹកប្រាក់ដ៏ច្រើនបែបនេះ អ្នករៀបចំគោលនយោបាយត្រូវតែខិតខំកៀរគររកប្រភពធនធានទាំងអស់ដែលមានសក្តានុពល ហើយពិចារណារកគម្រោង/កម្មវិធី បែបនវានុវត្តន៍សម្រាប់ហិរញ្ញប្បទានហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។

សម្រាប់ប្រទេសជាច្រើន វិស័យសាធារណៈតែឯងពុំមានលទ្ធភាពផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគដ៏ច្រើនបែបនេះបានឡើយ។ ដូច្នេះ ដើម្បីបំពេញតម្រូវការ មានជម្រើសមួយដែលរាជរដ្ឋាភិបាលមិនអាចមើលរំលងបាន គឺការលើកទឹកចិត្តដល់ការវិនិយោគពីវិស័យឯកជនលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។ ជាងនេះទៅទៀត ការចូលរួមពីវិស័យឯកជនអាចនាំមកនូវអត្ថប្រយោជន៍ផ្សេងៗលើសពីទុនវិនិយោគ។ តួយ៉ាងរួមមានអត្ថប្រយោជន៍សម្រាប់អ្នកប្រើប្រាស់ចុងក្រោយពីបរិយាកាសប្រកួតប្រជែង ក៏ដូចជាការកៀរគរជំនាញបច្ចេកទេស និងសមត្ថភាពគ្រប់គ្រងរបស់វិស័យឯកជនសម្រាប់ផលប្រយោជន៍សាធារណៈ។ ដោយសារតែមានការចូលរួមរបស់វិស័យឯកជននៅក្នុងហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ថ្មីៗនេះ ទើបប្រទេសជាច្រើនមានលទ្ធភាពអាចបង្កើនអត្រាគ្របដណ្តប់ និងប្រសិទ្ធផល នៃសេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។

នៅសតវត្សចុងក្រោយនេះ យើងឃើញមានការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងការរៀបចំ និងអភិបាលកិច្ចវិស័យទឹកស្អាត។ ដោយគិតចាប់ពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំ យើងឃើញថា បញ្ហាគ្រប់គ្រងបានវិវត្តឆ្ពោះទៅរកការបែងចែកធនធាន ការត្រួតពិនិត្យគុណភាព ការកែលម្អ ការថែទាំ និងការអភិរក្ស ជា

ឧទាហរណ៍ ការគ្រប់គ្រងលើតម្រូវការជាដើម។ លើសពីនេះទៅទៀត ក៏មានការវិវត្តយ៉ាងស៊ីជម្រៅផ្នែកគោលនយោបាយ ដូចជា ការបង្កើតគោលនយោបាយ និងការលើកកម្ពស់បែបបទថ្មី វិមជ្ឈការ វិសហមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន ការចូលរួម ភាពជាដៃគូ និងសមធម៌ លទ្ធភាពហិរញ្ញវត្ថុ និងនិរន្តរភាពបរិស្ថាន ហើយទាំងអស់នេះមាននៅក្នុងអភិក្រមគ្រប់គ្រងធនធានទឹកចម្រុះ (Integrated Water Resource Management Approach)។

ទន្ទឹមនឹងនេះ ដូចដែលបានឃើញតាំងពីទសវត្សរ៍ ១៩៩០ មក លទ្ធផល នៃការកើនឡើងភាពជាដៃគូជាមួយវិស័យឯកជនអន្តរជាតិ គឺតែងតែខុសពីការរំពឹងទុក ហើយបាននាំឲ្យមានការជជែកវែកញែកលក្ខណៈនយោបាយយ៉ាងខ្លាំង។ សព្វថ្ងៃនេះ យើងចាំបាច់ត្រូវតែពិចារណាដោះស្រាយបញ្ហាក្នុងបរិយាកាសមួយស្ងប់ស្ងាត់ ហើយកំណត់គោលការណ៍មូលដ្ឋានដោយផ្អែកទៅលើបទពិសោធន៍ពីប្រទេសផ្សេងៗគ្នា។ វាជាការចាំបាច់ផងដែរក្នុងការពិចារណាលើការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៅក្នុងលក្ខខណ្ឌ នៃការចូលរួមរបស់វិស័យឯកជន ជាពិសេស គឺនិន្នាការឆ្ពោះទៅរកកិច្ចសន្យាដែលមានហានិភ័យតិច (សេវាកម្ម កិច្ចសន្យាគ្រប់គ្រង និងការចាប់ផ្តើមគម្រោង/កម្មវិធី) អ្នកពាក់ព័ន្ធក្នុងវិស័យ (ក្នុងស្រុក និងតំបន់) និងការទទួលស្គាល់កាន់តែខ្លាំងឡើង នៃតួនាទីរបស់សេវាករឯកជន (ឧទាហរណ៍ សហគ្រាសខ្នាតតូចដែលភាគច្រើនមិនមែនជាវិស័យរៀបរយ)។

វិស័យទឹកស្អាត និងអនាម័យមានលក្ខណៈពិសេសជាច្រើនប្រមូលផ្តុំគ្នាដែលតែងតែធ្វើឲ្យកិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ និងឯកជនមានការលំបាក ដូចជា៖ ( i ) ការចំណាយថេរខ្ពស់ គួបផ្សំនឹងការវិនិយោគដែលមិនអាចចំណេញបានវិញភ្លាមៗ និងតម្រូវការពុំសូវមានភាពបត់បែន ធ្វើឲ្យវិស័យនេះក្លាយជាវិស័យមួយផ្តាច់មុខពិបាកនឹងមានការប្រកួតប្រជែង ( ii ) វិស័យទឹកស្អាត គឺជាសេចក្តីត្រូវការមូលដ្ឋាន ហើយគុណភាព នៃការទទួលបានសេវាកម្មមានផលប៉ះពាល់បន្ទាប់បន្សំលើសុខភាព សមភាពយេនឌ័រ និងបរិស្ថានដែលពាក់ព័ន្ធទៅនឹងផលប្រយោជន៍នយោបាយច្រើន ( iii ) ទឹកស្អាត និងអនាម័យ គឺជាបញ្ហាក្នុងមូលដ្ឋានដែលទាមទារឲ្យមានការគ្រប់គ្រងនៅមូលដ្ឋាន ក៏ប៉ុន្តែ សារៈសំខាន់ នៃផលប៉ះពាល់បន្ទាប់បន្សំ និងការគិតគូរអំពីវដ្តទឹកស្អាតយ៉ាងពេញលេញ ចាំបាច់ទាមទារឲ្យមានអភិក្រមគ្រប់គ្រងធនធានទឹកចម្រុះមួយ ( iv ) ការរៀបចំវិស័យនេះមានភាពស្មុគ្រស្មាញ គឺដោយសារចំនួនភាគីពាក់ព័ន្ធផង និងភាពបែកខ្ញែកគ្នាផង ( v ) វិស័យទឹកស្អាត និងអនាម័យមានបណ្តុំហានិភ័យច្រើនអនេក ដូចជា ហានិភ័យដែលពាក់ព័ន្ធទៅនឹងកិច្ចសន្យា ហានិភ័យដែលពាក់ព័ន្ធទៅនឹងការប្តូររូបិយវត្ថុបរទេស ហានិភ័យអនុអធិបតេយ្យភាព និងការជ្រៀតជ្រែកផ្នែកនយោបាយ និង ( vi ) ការកំណត់តម្លៃ គឺជាបញ្ហាស្មុគស្មាញ ដោយសារតែវិស័យនេះមានកម្មវត្ថុជាច្រើន ដូចជា ការប្រមូលថ្លៃដើមវិញ ប្រសិទ្ធភាពសេដ្ឋកិច្ច សមធម៌ និងតម្លៃសមរម្យ។

## ២. គោលបំណង នៃគោលការណ៍ណែនាំ

គោលការណ៍ណែនាំ ស្តីពីការជំរុញឲ្យវិស័យឯកជនចូលរួមក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទមានគោលបំណងផ្តល់នូវការណែនាំជាក់ស្តែង ដើម្បីបង្កើនប្រសិទ្ធភាព នៃការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធដោយផ្តោតទៅលើការកែលម្អលទ្ធភាពទទួលបានទឹកស្អាត និងអនាម័យសម្រាប់សហគមន៍ជនបទ។ គោលការណ៍ណែនាំនេះត្រូវបានបង្កើត និងរៀបចំ

ឡើងដោយផ្អែកទៅតាមបទពិសោធន៍កន្លងមក ដែលឆ្លុះបញ្ចាំងពីបញ្ហាសំខាន់នានាដែលរាជរដ្ឋាភិបាល និងក្រុមហ៊ុនបានជួបប្រទះក្នុងកិច្ចសហប្រតិបត្តិការរបស់ខ្លួន ព្រមទាំងឧត្តមានុវត្តន៍ដែលបានបង្កើតឡើង។

សម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទ ក៏ដូចជាមន្ទីរអភិវឌ្ឍន៍ជនបទខេត្តដែលមានឆន្ទៈជំរុញឲ្យមានការចូលរួមពីវិស័យឯកជន គោលការណ៍ណែនាំនេះក៏អាចជាការតម្រង់ទិស និងជាជម្រើសមួយក្នុងចំណោមជម្រើសជាច្រើនផ្សេងៗទៀតដើម្បីកែលម្អការផ្តល់សេវាកម្មហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។ គោលការណ៍ណែនាំនេះមិនមានគោលបំណងជំរុញឲ្យធ្វើឯកជនភាវូបនីយកម្ម ឬការគ្រប់គ្រងជាលក្ខណៈឯកជនលើរាល់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទដែលជាកម្មសិទ្ធសាធារណៈនោះឡើយ។ ជម្រើសរវាងការផ្តល់សេវាកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទដោយវិស័យសាធារណៈ និងឯកជន គប្បីប្រព្រឹត្តទៅដោយការវាយតម្លៃបែបសត្យានុម័តដើម្បីឆ្ពោះទៅបម្រើផលប្រយោជន៍សាធារណៈឲ្យបានល្អបំផុត ពោលគឺទ្រទ្រង់ដល់សុខុមាលភាពជារួម។ កត្តាដែលត្រូវយកមកពិចារណា រួមមាន កម្រិត នៃការផ្តល់សេវាកម្មបច្ចុប្បន្ន និងលក្ខខណ្ឌទ្រព្យសកម្ម តម្លៃសមរម្យសម្រាប់គ្រួសារ និងក្រុមហ៊ុនអត្រាគ្របដណ្តប់ នៃបណ្តាញ ប្រសិទ្ធភាព នៃប្រតិបត្តិការ ការថែរក្សាទ្រព្យសកម្មរយៈពេលវែង ព្រមទាំងនិរន្តរភាពសង្គម និងបរិស្ថាន។ ការសម្រេចចិត្តក៏ចាំបាច់ត្រូវតែធ្វើឡើងក្នុងក្របខណ្ឌពេលវេលាទៅតាមតម្រូវការកែលម្អ និងប្រភពហិរញ្ញវត្ថុដែលមាន។

គោលការណ៍ណែនាំនេះ ក៏ត្រូវបានចាត់ទុកជាដំណាក់កាលដំបូងសម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទធ្វើការពិចារណាទៅលើការចូលរួមរបស់វិស័យឯកជន ដោយផ្តល់ជូននូវជម្រើសទិសដៅគោលនយោបាយរួមមួយដែលត្រូវបានវាយតម្លៃ ដើម្បីបញ្ចូលជាផ្នែកមួយ នៃការពិចារណាលើយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ខ្លួនដោយផ្អែកទៅលើកាលៈទេសៈ និងសេចក្តីត្រូវការរបស់ប្រទេសជាតិ។ វាមិនមែនជាការបង្គាប់បញ្ជាលម្អិត ឬការណែនាំបច្ចេកទេសលើការអនុវត្ត នៃទិដ្ឋភាពជាក់លាក់ នៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ការរៀបចំកិច្ចសន្យា ឬបទបញ្ញត្តិនោះទេ។ មកដល់ពេលនេះ ជំនួយបច្ចេកទេសទូទៅជាច្រើនអាចរកបាន រួមទាំងពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងគណៈកម្មការអឺរ៉ុប។

## ៣. វិសាលភាព នៃគោលការណ៍ណែនាំ

គោលការណ៍ណែនាំ ស្តីពីការជំរុញឲ្យវិស័យឯកជនចូលរួមក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ជនបទ ត្រូវបានបង្កើត និងរៀបចំឡើងដោយផ្អែកទៅលើឯកសារពីប្រភពផ្សេងៗគ្នា ដោយដកស្រង់យកបទពិសោធន៍ នៃការចូលរួមពីវិស័យឯកជននៅក្នុងការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ទាំងនៅក្នុងប្រទេស និងតំបន់។ គោលការណ៍នានាក្នុងគោលការណ៍ណែនាំនេះត្រូវបានរៀបចំតាមរយៈដំណើរការ នៃការពិគ្រោះយោបល់ជាមួយក្រុមអ្នកជំនាញមកពីវិស័យសាធារណៈ និងវិស័យឯកជន ព្រមទាំងពីអង្គការមិនមែនរដ្ឋាភិបាល។ ក្រសួងអភិវឌ្ឍន៍ជនបទ ដែលបានធ្វើការយ៉ាងសកម្មជាមួយដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ និងអ្នកពាក់ព័ន្ធដទៃទៀត នឹងជួយទៅលើវិធីសាស្ត្រអនុវត្ត និងការកសាងសមត្ថភាពគោលនយោបាយសម្រាប់ការប្រើប្រាស់គោលការណ៍ទាំងនោះប្រកបដោយប្រសិទ្ធភាព ដោយគិតគូរពិចារណាពី

កាលៈទេសៈ និងសេចក្តីត្រូវការខុសៗគ្នា។ គោលការណ៍នានាដែលមានចែងក្នុងគោលការណ៍ណែនាំនេះនឹងមានការពិនិត្យ និងកែសម្រួល ដោយផ្អែកទៅលើ និងឆ្លុះបញ្ចាំងពីបទពិសោធន៍ នៃការអនុវត្តជាក់ស្តែង។

គោលការណ៍អនុវត្តជាក់ស្តែង ស្តីពីទឹកស្អាត និងអនាម័យជនបទសំដៅជាចម្បងលើក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ដែលទទួលខុសត្រូវក្នុងការផ្តល់សេវាកម្មទឹកស្អាត ភាពស្អាត និងអនាម័យជនបទ។ ស្ថាប័នដទៃទៀត ដូចជា វិស័យឯកជន អ្នកប្រើប្រាស់ និងដៃគូអភិវឌ្ឍន៍ ក៏អាចប្រើប្រាស់គោលការណ៍ណែនាំនេះ ដើម្បីបង្កើនការយល់ដឹងកាន់តែច្បាស់អំពីបញ្ហានៅចំពោះមុខ និងធ្វើជាវេទិកាសម្រាប់កិច្ចពិភាក្សាគោលនយោបាយ។

វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ទទួលស្គាល់ពីភាពសម្បូរបែប នៃតួអង្គជាច្រើនក្នុងវិស័យឯកជន ដូចជា វិនិយោគិនអន្តរជាតិ តួអង្គក្នុងប្រទេស និងថ្នាក់តំបន់ វិស័យឯកជនដែលមានសកម្មភាពស្នូលរបស់ខ្លួនមិនពាក់ព័ន្ធនឹងទឹកស្អាត (ដូចជា ក្រុមហ៊ុនសំណង់ជាដើម) រួមទាំងក្រុមហ៊ុនវិនិយោគរួមគ្នារវាងក្រុមហ៊ុនរដ្ឋ និងឯកជន ព្រមទាំងក្រុមហ៊ុនរដ្ឋកំពុងធ្វើប្រតិបត្តិការនៅបរទេស គឺសុទ្ធតែជាដៃគូវិស័យឯកជនដ៏មានសក្តានុពល។ គេមិនចាំបាច់កំណត់យកនិយមន័យតឹងរ៉ឹងពេកចំពោះវិស័យឯកជនទេ ដោយសារគោលការណ៍ និងការអនុវត្តរបស់ពួកគេត្រូវបានសម្របខ្លួនបានយ៉ាងល្អចំពោះភាពជាដៃគូភាគច្រើន។ លើសពីនេះ ស្ថាប័នមិនស្វែងរកប្រាក់ចំណេញ (អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហគមន៍) ដែលដើរតួនាទីសំខាន់ក្នុងការផ្តល់សេវាកម្មទឹកស្អាត និងអនាម័យ ក៏ត្រូវបានរាប់បញ្ចូលផងដែរ។

## ៤. គោលការណ៍ជំរុញឲ្យវិស័យឯកជនចូលរួមក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

### ៤.១ គោលការណ៍ទី ១៖ ធ្វើឲ្យមាននិរន្តរភាពហិរញ្ញវត្ថុ នៃគម្រោង/កម្មវិធីវិនិយោគវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

ដោយមិនគិតពីទំហំ/កម្រិត នៃការចូលរួមរបស់វិស័យឯកជន គម្រោង/កម្មវិធីវិនិយោគវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទាំងអស់ គួរគប្បីចាប់ផ្តើមពីការវាយតម្លៃកម្រិត នៃការប្រមូលយកថ្លៃដើមមកវិញពីអ្នកប្រើប្រាស់ចុងក្រោយ ប្រសិនបើ ក្នុងករណីមានការខ្វះខាត គេអាចកៀរគរធនធានហិរញ្ញវត្ថុពីប្រភពណាផ្សេងទៀតមកបាន។

ក្រសួងអភិវឌ្ឍន៍ជនបទនឹងវាយតម្លៃម្តងហើយម្តងទៀតពីទំហំសេវាកម្ម ជម្រើសបច្ចេកទេស និងការចំណាយមួយចំណែក និងមួយចំណែកទៀតទៅលើតម្រូវការនាពេលអនាគត តារាងតម្លៃ និងលទ្ធភាពបង់ និងឆន្ទៈក្នុងការចំណាយ (យ៉ាងហោចណាស់សម្រាប់គម្រោង/កម្មវិធីទំហំធំ)។ កម្រិត/ទំហំផ្តល់សេវាកម្មសមស្រប បំផុតនឹងត្រូវយកមកគិតគូរពិចារណាយ៉ាងប្រុងប្រយ័ត្នបំផុត ដើម្បីទទួលបានប្រយោជន៍ពីសេដ្ឋកិច្ចមាត្រដ្ឋាន (Economies of scale)។

ឧបត្ថម្ភធននៅតែចាំបាច់ ជាពិសេស ការងារអនាម័យនៅតំបន់ជនបទដែលជាតំបន់មានលទ្ធភាពបង់ទាប ហើយត្រូវការការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធធំៗ។ ក្រសួងអភិវឌ្ឍន៍ជនបទនឹងបញ្ជាក់ឲ្យច្បាស់

ពីកម្រិតឧបត្ថម្ភធន ចន្លោះពេល លក្ខណៈ/ប្រភេទ (ការតភ្ជាប់/ការប្រើប្រាស់) និងដំណើរការតម្រង់ទៅគោលដៅ (ដោយអាស្រ័យទៅលើស្ថានភាពនៅមូលដ្ឋាន ពិចារណាពីការកំណត់គោលដៅច្បាស់លាស់មួយដែលមានលក្ខណៈចម្រុះ និងសមរម្យ តាមរយៈការអង្កេតតាមគ្រួសារ ការកំណត់គោលដៅភូមិសាស្ត្រ ការជ្រើសរើសដោយខ្លួនឯង និងឧបត្ថម្ភធនដល់បច្ចេកវិទ្យាដែលអាចប្រើប្រាស់បានដោយជនក្រីក្រ)។ ការរៀបចំឲ្យមានឧបត្ថម្ភធនឲ្យគ្នាទៅវិញទៅមក គួរតែអនុញ្ញាតឲ្យមានភាពប្រែប្រួលនៅក្នុងមូលដ្ឋានអ្នកប្រើប្រាស់។

ជម្រើស នៃបច្ចេកវិទ្យាមួយនឹងកំណត់ទម្រង់ នៃការផ្តល់សេវាកម្មរយៈពេលច្រើនឆ្នាំ ដូច្នេះជម្រើសនោះគួរគប្បីស៊ីគ្នាទៅនឹងការពិចារណាផ្នែកបច្ចេកទេស និងលទ្ធភាពចំណាយ។ វាមានជម្រើសជាច្រើន ជាពិសេស សម្រាប់ការងារអនាម័យ ដូចជា ប្រព័ន្ធលូបង្ហូរទឹកនៅនឹងកន្លែងដែលមានកម្រិតខុសៗគ្នា និងសាមញ្ញបំផុត។ លើសពីនេះ ការធ្វើពិពិធកម្ម នៃការផ្តល់សេវាកម្មអាចជួយធានាបាននូវនិរន្តរភាពហិរញ្ញវត្ថុស្របពេល និងការបម្រើដល់គោលបំណងជួយគាំទ្រដល់ជនក្រីក្រ។ ក្រសួងអភិវឌ្ឍន៍ជនបទនឹងបង្កភាពងាយស្រួលក្នុងការធ្វើឲ្យប្រសើរឡើងនូវបរិក្ខានានា ដើម្បីឲ្យអ្នកប្រើប្រាស់អាចខិតទៅប្រើប្រាស់បច្ចេកវិទ្យាកាន់តែប្រសើរជាងមុន។

## ៤.២ គោលការណ៍ទី ២៖ ជំរុញឲ្យមានបរិយាកាសអំណោយផលដល់ការចូលរួមរបស់វិស័យឯកជន

ការទាក់ទាញវិស័យឯកជនចូលរួមដោយការជំរុញឲ្យមានបរិយាកាសល្អ និងផ្តល់លទ្ធភាពវិនិយោគវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទពិតជាមានសារៈសំខាន់ណាស់។ នេះសំដៅដល់កម្រិតស្តង់ដាខ្ពស់ នៃអភិបាលកិច្ចសាធារណៈ និងសាជីវកម្ម តម្លាភាព និងនីតិរដ្ឋ រួមទាំងការការពារកម្មសិទ្ធបញ្ញា និងសិទ្ធចែងក្នុងកិច្ចសន្យា។

ដូចវិស័យដទៃទៀតដែរ ជោគជ័យ នៃការចូលរួមពីវិស័យឯកជនក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទពឹងផ្អែកជាចម្បងទៅលើគុណភាព នៃបរិយាកាសវិនិយោគក្នុងស្រុក។ វិស័យសាធារណៈនឹងនៅតែជាអ្នកជួយជំរុញគុណភាព នៃបរិយាកាសធុរកិច្ច និងអភិបាលកិច្ចសាជីវកម្មដែលអាស្រ័យទៅលើលិខិតបទដ្ឋានគតិយុត្តិ ការប្រតិបត្តិរដ្ឋបាល និងគោលនយោបាយ និងសង្គតិភាព នៃគោលនយោបាយ។ ភាពជោគជ័យ គឺអាស្រ័យទៅលើច្បាប់ និងការអនុវត្តរដ្ឋបាលជាច្រើនដែលទាក់ទងទៅនិងក្រុមហ៊ុនឯកជន បុគ្គលិករបស់ខ្លួនអ្នកពាក់ព័ន្ធនានា សមត្ថភាពរបស់អ្នកផ្គត់ផ្គង់ក្នុងស្រុក និងអ្នកម៉ៅការបន្ត ក្នុងការចាប់ដៃគូជាមួយសេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។ នៅក្នុងបរិយាកាសមិនអាចអនុវត្តច្បាប់ និងកិច្ចព្រមព្រៀងបានគ្រប់គ្រាន់ លក្ខណៈវិនិច្ឆ័យជោគជ័យដទៃទៀតភាគច្រើនមានសារៈសំខាន់បន្ទាប់បន្សំតែប៉ុណ្ណោះ។ នេះជាករណីជាជាពិសេស នៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទសម្រាប់គម្រោង/កម្មវិធីមធ្យម ឬធំ ដែលម្ចាស់កម្មសិទ្ធទ្រព្យសកម្មគឺកាន់កាប់ដោយវិស័យឯកជន ហើយពិបាកសម្រាប់វិនិយោគិនក្នុងការចាកចេញពីវិស័យនេះ។ ដូចនេះ ក្រសួងអភិវឌ្ឍន៍ជនបទនឹងរៀបចំលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនានាក្នុងដំណើរការប្រកបដោយតម្លាភាព ដែលធានាបាននូវការពិគ្រោះយោបល់ជាមុនជាមួយវិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀត។ ការធ្វើសមាហរណកម្មតួអង្គឯកជនខ្នាតតូចនៅក្នុងខ្សែសង្វាក់ នៃការផ្តល់សេវាកម្មឲ្យបានល្អជាងមុន អាចតម្រូវឲ្យមានទម្រង់ នៃការទទួលស្គាល់ជាផ្លូវការអំពីភាពស្របច្បាប់ នៃសកម្មភាពរបស់ខ្លួន។

### ៤.៣ គោលការណ៍ទី ៣៖ បង្កើតបរិយាកាសប្រកួតប្រជែងដោយត្រឹមត្រូវ និងស្មើភាពគ្នា

កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតបរិយាកាសប្រកួតប្រជែងដោយត្រឹមត្រូវ និងស្មើភាពគ្នា តាមរយៈការដកចេញនូវឧបសគ្គដែលមិនចាំបាច់ក្នុងការពង្រឹងការអនុវត្តច្បាប់ ស្តីពីការប្រកួតប្រជែងជាធរមាន អាចលើកកម្ពស់អត្ថប្រយោជន៍ នៃការចូលរួមរបស់វិស័យឯកជនក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទបាន។

ភាពផ្តាច់មុខនៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទធ្វើឲ្យមានការលំបាកក្នុងការបង្កើតលក្ខខណ្ឌសម្រាប់ការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាព។ ក្រសួងអភិវឌ្ឍន៍ជនបទនឹងសម្រេចឲ្យបានលទ្ធផលល្អបំផុត តាមរយៈការដាក់សម្ពាធ និងជំរុញឲ្យមានការប្រកួតប្រជែង ខណៈពេលដែលភាពផ្តាច់មុខឬការប្រកួតប្រជែងមិនស្មើភាពគ្នា/មិនពេញលេញអាចអនុវត្តបាន ផ្អែកតាមបទបញ្ញត្តិ នៃលិខិតបទដ្ឋាន និងបម្រើប្រយោជន៍សាធារណៈ។ បរិយាកាសវិនិយោគបើកចំហជាអន្តរជាតិនឹងជួយសម្រួលដល់ការប្រកួតប្រជែង និងបង្កើនអត្ថប្រយោជន៍ តាមរយៈការបង្កើនចំនួនអ្នកចូលរួមដែលមានសក្តានុពល និងពង្រីក "ទីផ្សារពាក់ព័ន្ធ" ទៅក្រៅប្រទេស។ ដើម្បីសម្រេចបាននូវអត្ថប្រយោជន៍ទាំងនេះ ក្រសួងអភិវឌ្ឍន៍ជនបទនឹងរក្សាឲ្យបាននូវបរិយាកាសវិនិយោគបើកចំហ និងមិនរើសអើង ដោយធានាថាទាំងក្រុមហ៊ុនក្នុងស្រុក និងមកពីបរទេសអាចប្រកួតប្រជែងដោយត្រឹមត្រូវ និងស្មើភាពគ្នា អនុលោមតាមស្តង់ដាការងារ និងស្តង់ដាអន្តរជាតិផ្សេងទៀតដែលមានការទទួលស្គាល់ដោយប្រតិបត្តិករទាំងអស់។

លក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យានឹងត្រូវបានពិនិត្យពិច័យ និងថ្លឹងថ្លែងយ៉ាងហ្មត់ចត់ ដើម្បីធានាបានការស្មើភាព និងតុល្យភាពរវាងគូភាគី។ ទាំងនេះរួមមានហានិភ័យដែលវិនិយោគិនមានលទ្ធភាព នៃការពិភាក្សា ឬកែសម្រួលលក្ខខណ្ឌក្នុងកិច្ចសន្យា រយៈពេល នៃកិច្ចសន្យា (ដែលលើកទឹកចិត្តដល់ការវិនិយោគលើការជួសជុល និងថែទាំ) និងសំណើសុំដាក់ដេញថ្លៃដោយមានការប្រកួតប្រជែងញឹកញាប់ជាងមុន។

នៅពេលមានការពង្រីកបណ្តាញ និងការតភ្ជាប់ចូលខ្នងផ្ទះមានភាពយឺតយ៉ាវ ក្រសួងអភិវឌ្ឍន៍ជនបទនឹងពិចារណាលើការបើកទីផ្សារ និងលើកទឹកចិត្តដល់សេវាករផ្សេងទៀតក្នុងការពន្លឿនការផ្តល់សេវាកម្មជូនអ្នកក្រីក្រក្នុងតម្លៃល្អជាងមុន។ ក្រសួងអភិវឌ្ឍន៍ជនបទក៏នឹងធានាថា សេវាករខ្នាតតូចមិនត្រូវបានលុបចេញពីទីផ្សារទេ ប៉ុន្តែ ក៏មិនដាក់ពួកគាត់ក្នុងក្រុមផ្តាច់មុខដោយគ្មានការប្រកួតប្រជែងផងដែរ។

ការប្រកួតប្រជែងជាគោល ឬគំរូមួយនឹងត្រូវបានរៀបចំដើម្បីប្រៀបធៀបលទ្ធផលការងារក្នុងចំណោមអ្នកផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងផ្សព្វផ្សាយព័ត៌មានដល់សាធារណជន។ ការអនុវត្ត និងទម្រង់ច្បាប់នឹងត្រូវបានកំណត់ឲ្យប្រសើរជាងមុន ដើម្បីឲ្យប្រតិបត្តិករទឹកស្អាតនៅតំបន់ជនបទអាចប្រតិបត្តិនៅកម្រិតដែលអាចប្រកួតប្រជែងគ្នាជាមួយដៃគូប្រកួតប្រជែងឯកជន និងអភិវឌ្ឍន៍នូវចំណុចដៅផ្សេងៗទៀត។ នីតិវិធីរដ្ឋបាល និងការរៀបចំលិខិតបទដ្ឋានគតិយុត្តិនឹងមានសង្គតិភាពទូទាំងវិស័យទាំងមូល ដើម្បីលើកទឹកចិត្តឲ្យមានការប្រៀបធៀប និងការប្រកួតប្រជែងដោយត្រឹមត្រូវ និងស្មើភាពគ្នា។

### ៤.៤ គោលការណ៍ទី ៤៖ ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

ក្រសួងអភិវឌ្ឍន៍ជនបទនឹងសម្របសម្រួលឲ្យមានការពិគ្រោះយោបល់ជាមួយអ្នកប្រើប្រាស់ចុងក្រោយ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត រួមទាំងមុនពេលចាប់ផ្តើមអនុវត្តគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។ ក្រសួងអភិវឌ្ឍន៍ជនបទនឹងធានាជាមុនថា កិច្ចការដែលរំពឹងទុកគឺសុទ្ធតែបម្រើផលយោជន៍សាធារណៈ ហើយអ្នកប្រើប្រាស់ និងអ្នកពាក់ព័ន្ធនានាអាចទទួលយកបាន រួមទាំងការពិគ្រោះយោបល់ជាមួយភាគីដែលរងផលប៉ះពាល់ទាំងអស់ និងកំណត់ការរំពឹងទុកដែលវិស័យឯកជនអាចសម្រេចបានពិតប្រាកដ។

កិច្ចពិគ្រោះយោបល់ជាសាធារណៈនឹងត្រូវបានរៀបចំ ដោយអនុលោមទៅតាមគោលការណ៍ នៃការផ្តោតជាក់លាក់ ភាពជាតំណាងច្បាស់លាស់ និងមានតម្លាភាព ហើយអនុវត្តតាមនីតិវិធីស្តង់ដាដែលមានស្រាប់។ ដោយសារ វាទាមទារពេលវេលា និងធនធាន ដូច្នេះ ទើបការពិគ្រោះយោបល់អាចធ្វើឡើងនៅដំណាក់កាលសំខាន់ៗ នៃការរៀបចំគោលនយោបាយ ហើយប្រសើរបំផុតនៅដំណាក់កាលដំបូង នៃការចាប់ផ្តើមគម្រោង/កម្មវិធី។ កិច្ចពិគ្រោះយោបល់នេះនឹងរួមបញ្ចូលមតិយោបល់ច្បាស់លាស់ពីសំណាក់អាជ្ញាធរសាធារណៈ។ ក្រសួងអភិវឌ្ឍន៍ជនបទនឹងរៀបចំការបណ្តុះបណ្តាល និងជំរុញឲ្យមានការចូលរួមពីសហគមន៍ទន់ខ្សោយជាពិសេស ការចូលរួមយ៉ាងសកម្មពីសំណាក់សង្គមស៊ីវិល (អង្គការមិនមែនរដ្ឋាភិបាល និងក្រុមអ្នកប្រើប្រាស់) ក្នុងការការពារសិទ្ធអ្នកប្រើប្រាស់ ការត្រួតពិនិត្យ ការផ្តល់សេវាកម្ម និងការកំណត់យកគំរូ នៃការគ្រប់គ្រងការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាព។

យន្តការសម្របសម្រួលនឹងត្រូវបានរៀបចំឡើង តាមរយៈការសម្របសម្រួលឲ្យមានការយល់ដឹងកាន់តែច្បាស់ពីភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធទាំងអស់ តាមរយៈការបង្កើនសមត្ថភាព និងលំហសម្រាប់កិច្ចសន្ទនា។ លើសពីនេះទៅទៀត ក្រសួងអភិវឌ្ឍន៍ជនបទនឹងបង្កើនទំនុកចិត្ត និងការយល់ដឹងរបស់អ្នកប្រើប្រាស់តាមរយៈយុទ្ធនាការផ្តល់ព័ត៌មានអំពីគោលនយោបាយសាធារណៈ និងការបញ្ចេញព័ត៌មានគម្រោង/កម្មវិធី សំខាន់ៗ ក៏ដូចជាលទ្ធផលរំពឹងទុក។

### ៤.៥ គោលការណ៍ទី ៥៖ ប្រាស្រ័យទាក់ទងរវាងអ្នកអនុវត្តការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ជនបទ

ដើម្បីបង្កើនប្រសិទ្ធភាព នៃការចូលរួមរបស់វិស័យឯកជន ក្រសួងអភិវឌ្ឍន៍ជនបទនឹងផ្សព្វផ្សាយឲ្យបានច្បាស់អំពីវត្ថុបំណង នៃគោលនយោបាយហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យជនបទ និងដាក់ចេញនូវយន្តការសម្រាប់ពិគ្រោះយោបល់រវាងដៃគូសាធារណៈ និងឯកជនពាក់ព័ន្ធ និងកម្មវត្ថុទាំងនេះក៏ដូចជាគម្រោង/កម្មវិធីនីមួយៗផងដែរ។

ការកសាងទំនុកចិត្តរវាងវិស័យសាធារណៈ និងវិស័យឯកជន គឺជាបញ្ហាអាទិភាពខ្ពស់បំផុត។ វាជាការចម្លែកបន្តិចដែលសហគ្រាសឯកជននានាសម្រេចចិត្តចូលរួមក្នុងគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនៅក្នុងប្រទេសដែលគេចាត់ទុកថា បរិយាកាសមិនអំណោយផលល្អសម្រាប់ការវិនិយោគ។ ប្រសិនបើភាគីទាំងពីរត្រូវបានធ្វើការរួមគ្នាក្នុងបរិយាកាសវិនិយោគដ៏លំបាកមួយ ដូចនេះ វាចាំបាច់ឲ្យមានភាពបើកចំហ ឬការបត់បែនក្នុងកម្រិតណាមួយអំពីអ្វីដែលត្រូវសម្រេចឲ្យបាន ហើយដោយមធ្យោបាយណា ដើម្បីធានាដល់ដៃគូ និងចៀសវាងការយល់ច្រឡំដែលនាំឲ្យមានការខាតបង់ច្រើន។

ក្រសួងអភិវឌ្ឍន៍ជនបទនឹងបង្កើនសមត្ថភាព និងលំហសម្រាប់កិច្ចសន្ទនារវាងវិស័យសាធារណៈ និងវិស័យឯកជន។ មធ្យោបាយទំនាក់ទំនងអាចមានភាពខុសប្លែកគ្នាទៅតាមអ្នកពាក់ព័ន្ធ ដែលអាស្រ័យទៅលើវត្តមាន នៃសមាគមអាជីវកម្ម និងថាតើវិស័យនេះផ្លូវការ ឬក្រៅផ្លូវការ។ ក្រសួងអភិវឌ្ឍន៍ជនបទក៏នឹងជំរុញការសន្ទនាក្នុងចំណោមប្រតិបត្តិករ ដើម្បីលើកទឹកចិត្តដល់ការចែករំលែកឧត្តមានុវត្តន៍ និងការកសាងសមត្ថភាព។

វិស័យឯកជន គួរគប្បីចូលរួមចំណែកក្នុងការរៀបចំយុទ្ធសាស្ត្រក្នុងការប្រាស្រ័យទាក់ទង និងពិគ្រោះយោបល់ជាសាធារណៈ រួមបញ្ចូលទាំងអ្នកប្រើប្រាស់ សហគមន៍ដែលរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធអាជីវកម្មក្នុងគោលបំណងបង្កើតការទទួលយក និងការយោគយល់គ្នាទៅវិញទៅមកចំពោះវត្ថុបំណងរបស់ភាគីពាក់ព័ន្ធ។ ដើម្បីធ្វើដូច្នេះ ក្រសួងអភិវឌ្ឍន៍ជនបទនឹងអនុវត្តសកម្មភាពដូចខាងក្រោម៖

- អនុញ្ញាតឲ្យក្រុមហ៊ុនចូលរួមក្នុងដំណើរការត្រួតពិនិត្យ និងទំនាក់ទំនង នៅពេលដែលស្ថាប័ន/បញ្ញត្តិករសាធារណៈ ដាក់ចេញឲ្យអនុវត្តដំណើរការនេះ។
- លើកទឹកចិត្តឲ្យក្រុមហ៊ុនមានភាពឆ្លើយតបទាន់ពេលវេលាចំពោះការទាមទាររបស់អតិថិជន និងអនុវត្តនីតិវិធីប្រកបដោយតម្លាភាព និងប្រសិទ្ធភាព ដើម្បីដោះស្រាយបណ្តឹងរបស់អតិថិជន។
- អនុញ្ញាតឲ្យក្រុមហ៊ុនចូលរួមក្នុងយុទ្ធនាការលើកកម្ពស់ការយល់ដឹង (ជាឧទាហរណ៍ ពាក់ព័ន្ធទៅនឹងអនាម័យ)។
- លើកទឹកចិត្តឲ្យក្រុមហ៊ុនធ្វើការទំនាក់ទំនងទៅអ្នកប្រើប្រាស់អំពីហេតុផល នៃការដំឡើងថ្លៃ (ប្រសិនបើមាន) និងការផ្លាស់ប្តូរសំខាន់ៗផ្សេងទៀតក្នុងការផ្តល់សេវាកម្ម និងឲ្យស្របតាមគុណភាពសេវាកម្ម និងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់។

## ៤.៦ គោលការណ៍ទី ៦៖ បញ្ចេញព័ត៌មានដែលពាក់ព័ន្ធទៅនឹងគម្រោង/កម្មវិធី

ព័ត៌មានដែលពាក់ព័ន្ធទៅនឹងគម្រោង/កម្មវិធីរវាងអាជ្ញាធរសាធារណៈ និងដៃគូឯកជនត្រូវបានចែករំលែក និងបញ្ចេញ រួមទាំងស្ថានភាពមុនមានហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ស្តង់ដាអនុវត្តការងារ និងពិន័យផ្សេងៗក្នុងករណីមិនប្រតិបត្តិតាម។ ក្រសួងអភិវឌ្ឍន៍ជនបទនឹងប្រកាន់ខ្ជាប់គោលការណ៍កិច្ចការពារដោយប្រុងប្រយ័ត្ន (Due Diligence Principle) ដោយពិនិត្យទៅលើសក្តានុពល និងដឹងពីព័ត៌មានទាំងឡាយរបស់ក្រុមហ៊ុន មុនពេលសម្រេចថានឹងចុះកិច្ចព្រមព្រៀងវិនិយោគជាមួយគ្នា។

គោលការណ៍កិច្ចការពារនេះក៏សំដៅផងដែរថា ក្រសួងអភិវឌ្ឍន៍ជនបទនឹងអនុវត្តសកម្មភាពដោយប្រុងប្រយ័ត្ន ដើម្បីកាត់បន្ថយហានិភ័យណាមួយដល់ភាគីដទៃទៀត ឬដល់ខ្លួនឯង។ ក្នុងការអនុវត្តជាក់ស្តែង ចំណុចនេះសំដៅដល់ហានិភ័យដែលអាចប្រមើមើលឃើញជាមុនដើម្បីត្រៀមបង្ការ និងបញ្ចៀស ព្រមទាំងចែករំលែកព័ត៌មានជាចាំបាច់ដោយមិនបិទខ្ទប់ព័ត៌មានសំខាន់ណាមួយឡើយ។ ការខកខានមិនបានអនុវត្តបែបនេះនឹងចាត់ទុកថាជាការធ្វេសប្រហែស។

ព័ត៌មានដែលទាក់ទងទៅនឹងគម្រោង/កម្មវិធីជាមួយដៃគូវិស័យឯកជននឹងត្រូវចែករំលែកជាទូទៅ។ ប្រសិនបើគ្មានព័ត៌មានបច្ចេកទេស សេដ្ឋកិច្ច និងបរិស្ថានគ្រប់គ្រាន់សម្រាប់វិនិយោគិនដែលនឹងមកវិនិយោគទេនោះ គម្រោង/កម្មវិធីប្រឈមនឹងហានិភ័យខ្ពស់តាំងពីចាប់ផ្តើមដំបូង។ ក្នុងករណីដែលមានការបិទខ្ទប់ព័ត៌មានមួយចំនួន ឬចែករំលែកព័ត៌មានមិនបានពេញលេញនោះ វិស័យឯកជនខ្លះអាចនឹងដកខ្លួនចេញពីគម្រោង/កម្មវិធី រីឯខ្លះទៀតអាចយល់ឃើញថា ជាការផ្តល់ភាពមិនច្បាស់លាស់ ថាតើកិច្ចសន្យាអាចនឹងបន្ត ឬក៏អាចកែប្រែលក្ខខណ្ឌក្នុងកិច្ចសន្យាបាន។ នៅពេលដែលគ្មានព័ត៌មានច្បាស់លាស់អំពីគម្រោង/កម្មវិធី ហើយគូភាគីដែលចុះកិច្ចសន្យាផ្អែកតែទៅលើការប៉ាន់ប្រមាណ នោះនឹងមានការកែប្រែកិច្ចសន្យានៅពេលអនាគត ដោយចៀសមិនផុត។

ក្រសួងអភិវឌ្ឍន៍ជនបទនឹងចែករំលែកព័ត៌មានអំពីការអនុវត្តចំពោះគម្រោង/កម្មវិធីនីមួយៗ និងការបំពេញកាតព្វកិច្ចរបស់វិស័យឯកជនដែលចូលរួមក្នុងដំណើរការទាំងអស់។ ក្នុងករណីមិនបានបំពេញកាតព្វកិច្ចដូចបានព្រមព្រៀង វិធានការផ្លូវច្បាប់ ឬពិន័យផ្សេងៗនឹងកំណត់ទុកជាមុន។

## ៤.៧ គោលការណ៍ទី ៧៖ រៀបចំកិច្ចសន្យាដែលត្រូវធ្វើឡើងដោយត្រឹមត្រូវ គ្មានការរើសអើង និងមានតម្លាភាព

ការរៀបចំកិច្ចសន្យាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ គឺត្រូវតែអនុលោមតាមនីតិវិធីដែលធានាបាននូវភាពត្រឹមត្រូវ គ្មានការរើសអើង និងប្រកបដោយតម្លាភាព។

ការវាយតម្លៃការដាក់ដេញថ្លៃ គឺជាកិច្ចការមួយដ៏សំខាន់សម្រាប់វាយតម្លៃសមត្ថភាពហិរញ្ញវត្ថុ និងបច្ចេកទេសរបស់ដៃគូឯកជនក្នុងការអនុវត្ត និងសម្រេចលទ្ធផលគម្រោង/កម្មវិធី។ កំណត់ត្រាតាមដាន និងបទពិសោធន៍កន្លងមកអាចជាការចង្អុលបង្ហាញ នៃសមត្ថភាពអនុវត្តការងារ ប៉ុន្តែ មិនគួរពិចារណាតាមបែបចង្អៀតពេកទេក្នុងការដកយកក្រុមហ៊ុនតូចៗចេញ ឬដាក់កម្រិតលើការប្រកួតប្រជែង។ របាយការណ៍វាយតម្លៃនឹងត្រូវបានរៀបចំ ដើម្បីរៀបរាប់ពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដេញថ្លៃ ការថ្លែងបញ្ជាក់ពីសេវាកម្មដែលផ្តល់ឲ្យ មានសំណើសាងសង់ ហានិភ័យដែលអាចមានចំពោះរាជរដ្ឋាភិបាល សមត្ថភាពបច្ចេកទេស និងហិរញ្ញវត្ថុរបស់ដៃគូឯកជន ភាពបត់បែននានាដើម្បីសម្របទៅតាមការផ្លាស់ប្តូរ។

នៅក្នុងការរៀបចំកិច្ចសន្យា គួរតែពិចារណាចំណុចទាំងឡាយដូចខាងក្រោម៖

- ចំណុចប្រទាញប្រទង់គ្នារវាងកិច្ចសន្យាលម្អិត និងភាពបត់បែន នៃកិច្ចសន្យា។ ក្នុងការកំណត់លក្ខណៈពិសេស នៃការព្រមព្រៀងគ្នា នឹងមានការកំណត់ផលវិបាកលើការលើកទឹកចិត្តសម្រាប់វិស័យឯកជន រួមទាំងរយៈពេល (តុល្យភាព ការប្តេជ្ញាចិត្តរបស់វិស័យឯកជន ការប្រកួតប្រជែង និងហានិភ័យរបស់វិស័យឯកជន ឬរាជរដ្ឋាភិបាល) ការវិនិយោគ និងកាតព្វកិច្ចអនុវត្ត/សម្រេចលទ្ធផលការងារ ការបែងចែកហានិភ័យ ការចំណាយទៅលើការកំណត់មូលធន ការវាយតម្លៃទ្រព្យសម្បត្តិសម្បទាន និងគោលបំណងជួយគាំទ្រដល់អ្នកក្រីក្រ។
- ដាក់បញ្ចូលធាតុផ្សំ នៃបញ្ញត្តិ (ដូចជា កម្រិតតម្លៃ អត្រា នៃប្រាក់ចំណេញ សេចក្តីណែនាំលើការកែប្រែតម្លៃ និងតម្លៃដែលគាំទ្រដល់សង្គម) និងគោលការណ៍ដោះស្រាយវិវាទ (ការធានាលទ្ធផល

ការងារ ការចរចា ឬការកែសម្រួលឡើងវិញនូវលក្ខខណ្ឌ នៃកិច្ចសន្យា ឧបាស្រ័យទៅមជ្ឈត្តកម្មអន្តរជាតិ គណៈកម្មការត្រួតពិនិត្យអចិន្ត្រៃយ៍ និងគណៈកម្មការដោះស្រាយវិវាទអចិន្ត្រៃយ៍) ទៅក្នុងកិច្ចសន្យា។

- ពិនិត្យមើលកិច្ចសន្យា ឯកសារពាក់ព័ន្ធ និងដំណើរការថាតើអនុលោមតាមលិខិតបទដ្ឋានគតិយុត្តិឬអត់។ ប្រសិនបើ ច្បាប់តម្រូវឲ្យមានការផ្លាស់ប្ដូរដែលប៉ះពាល់ដល់កិច្ចសន្យានោះ គេគួរតែធ្វើការផ្លាស់ប្ដូរ មុនពេលកិច្ចសន្យានោះចូលជាធរមាន។

នៅក្នុងដំណើរការចុះកិច្ចសន្យា គួរតែពិចារណាចំណុចទាំងឡាយដូចខាងក្រោម៖

- ធានាឲ្យបាននូវភាពច្បាស់លាស់ និងតម្លាភាព នៃបញ្ញត្តិនានាសម្រាប់ភាគីពាក់ព័ន្ធទាំងអស់រួមទាំងបញ្ជាក់ឲ្យបានច្បាស់អំពីលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃ ។
- បង្កើនឱកាសសម្រាប់ការប្រកួតប្រជែង
- កាត់បន្ថយឱកាសក្នុងការឃុបឃិតគ្នា និងការចរចាឡើងវិញ ដើម្បីកែសម្រួលលក្ខខណ្ឌនាពេលអនាគត ដោយការជ្រើសរើសលក្ខណៈពិសេសណាមួយ (ចំនួនប្រតិបត្តិករ និងការសម្របសម្រួលរបស់ខ្លួន) និងលក្ខណៈវិនិច្ឆ័យក្នុងការផ្ដល់កិច្ចសន្យា។
- លក្ខណៈវិនិច្ឆ័យក្នុងការផ្ដល់កិច្ចសន្យាគួរតែរៀបចំឲ្យសាមញ្ញៗ ងាយយល់ ដើម្បីសម្រួលដល់ការរៀបចំឯកសារដេញថ្លៃ ដោយផ្ដោតទៅលើបរិមាណ គុណភាព និងតម្លៃ នៃសេវាកម្មដែលត្រូវផ្ដល់ជូន។

### ៤.៨ គោលការណ៍ទី ៨៖ រៀបចំកិច្ចសន្យាដោយផ្អែកទៅលើការអនុវត្ត/លទ្ធផលការងារ

កិច្ចព្រមព្រៀងផ្លូវការរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូជាវិស័យឯកជននឹងបញ្ជាក់អំពីសេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទជាក់លាក់ដែលត្រូវផ្ដល់ជូនសាធារណជន ដោយផ្អែកទៅតាមការបរិយាយលម្អិតពីការអនុវត្ត ឬលទ្ធផលការងារដែលត្រូវសម្រេចឲ្យបាន។ កិច្ចព្រមព្រៀងនេះក៏នឹងមានការចែងអំពីការបែងចែកការទទួលខុសត្រូវ និងការគ្រប់គ្រងហានិភ័យក្នុងករណីមានព្រឹត្តិការណ៍ណាមួយកើតឡើងដោយមិនបានព្រៀងទុក។

កិច្ចសន្យានឹងកំណត់ច្បាស់លាស់ពីវិសាលភាព នៃគម្រោង/កម្មវិធី (គោលបំណងដែលត្រូវសម្រេចសិទ្ធ កាតព្វកិច្ច និងការទទួលខុសត្រូវ នៃគូភាគីទាំងអស់) កំណត់គោលដៅដែលមិនផ្ទុយគ្នា និងចៀសវាងការដាក់លក្ខខណ្ឌលើសលុប (ឧទាហរណ៍ ការប្រចាប់បញ្ចូលគ្នា នៃគោលដៅលទ្ធផលការងារ និងកាតព្វកិច្ចវិនិយោគ) និងការផ្ទុយ/ប្រាសចាកពីក្របខ័ណ្ឌច្បាប់ជាធរមាន។ វាមានការកំណត់រយៈពេលផុតកំណត់ជាក់ស្ដែង ពីព្រោះពេលខ្លះលទ្ធផលមិនអាចសម្រេចបានក្នុងរយៈពេលខ្លីពេក។ កិច្ចសន្យាក៏នឹងបញ្ជាក់អំពីក្របខ័ណ្ឌសម្រាប់ការចរចាលក្ខខណ្ឌថ្មីណាមួយ រួមទាំងខចែង និងយន្តការនានាដើម្បីកំណត់កិច្ចពិភាក្សាលើបញ្ហានាពេលអនាគត និងនីតិវិធីដោះស្រាយវិវាទជាផ្លូវការ។

ក្រសួងអភិវឌ្ឍន៍ជនបទនឹងធ្វើនិយ័តកម្ម និងត្រួតពិនិត្យ តាមដានជាតុចេញជាជាងធាតុចូល។ ចៀសវាងការបញ្ជាក់សេវាកម្មបច្ចេកទេសលម្អិតពេក ពីព្រោះ ប្រការនេះអាចដាក់កំហិតជម្រើសផ្សេងៗ និងអាចមិនផ្តល់ប្រយោជន៍ដល់អ្នកក្រីក្រ។ ការសម្រាលស្តង់ដាបច្ចេកទេសខ្លះ (ដូចជា ទំហំអង្កត់ផ្ចិតបំពង់បង្ហូរ ជម្រាល និងជម្រៅ) អាចធ្វើឲ្យគម្រោង/កម្មវិធីអភិវឌ្ឍន៍ថោកជាងមុន ក្លាយជាប្រព័ន្ធមួយជួយគាំទ្រដល់អ្នកក្រីក្រ និងឆ្លុះបញ្ចាំងពីតម្រូវការរបស់អ្នកប្រើប្រាស់។

មូលដ្ឋានសម្រាប់ទំនាក់ទំនងរវាងអាជ្ញាធរសាធារណៈដែលទទួលខុសត្រូវ និងប្រតិបត្តិករឯកជន គឺជាការរៀបចំកិច្ចសន្យាផ្លូវការ។ ទំនាក់ទំនងដែលគ្មានកិច្ចសន្យាគឺជាសមាសធាតុសំខាន់ នៃការប្រាស្រ័យទាក់ទងរវាងតួអង្គរដ្ឋ និងឯកជន ប៉ុន្តែ ប្រព័ន្ធនេះចាំបាច់ត្រូវតែធ្វើឲ្យទៅជាប្រព័ន្ធផ្លូវការវិញ ប្រសិនបើ មានការប្រើប្រាស់ប្រព័ន្ធប្រាស្រ័យទាក់ទងគ្នាក្រៅផ្លូវការច្រើនលើសលុបពេក។ កិច្ចសន្យាពិពណ៌នាយ៉ាងច្បាស់លាស់អំពីប្រការ និងយន្តការទាំងឡាយ ដើម្បីកំណត់កិច្ចពិភាក្សាអំពីបញ្ហានាពេលអនាគត (រួមទាំងការដោះស្រាយផលវិបាក នៃព័ត៌មានមិនគ្រប់គ្រាន់) ក៏ដូចជាយន្តការដោះស្រាយវិវាទផ្លូវការផងដែរ។ អ្វីដែលល្អប្រសើរ គឺត្រូវតែចាប់ផ្តើមកិច្ចពិភាក្សានេះឲ្យបានឆាប់នៅពេលមានបញ្ហាប្រឈមកើតឡើង និងមុនពេលជម្លោះរីករាលដាលធំទៅៗ។ ក្រសួងអភិវឌ្ឍន៍ជនបទនឹងឲ្យដៃគូជាវិស័យឯកជនចូលរួមចំណែកក្នុងការរៀបចំលក្ខខណ្ឌតម្រូវការនានាដែលត្រូវបំពេញ និងកំណត់ពីបញ្ហាលំបាក ឬបញ្ហាប្រឈមនានា ដើម្បីឈានទៅរកការរៀបចំកិច្ចសន្យាមួយដោយឈរលើគោលការណ៍យោគយល់គ្នាទៅវិញទៅមក និងត្រឹមត្រូវប្រសើរជាងមុន។

### ៤.៩ គោលការណ៍ទី ៩៖ អនុញ្ញាតឲ្យមានការចរចាកែសម្រួលលក្ខខណ្ឌឡើងវិញ ដោយឈរលើគោលការណ៍ត្រឹមត្រូវ ស្មោះត្រង់ តម្លាភាព និងគ្មានការរើសអើង

ការចរចា ឬការកែសម្រួលយូរៗម្តងនូវលក្ខខណ្ឌណាមួយក្នុងកិច្ចសន្យា គឺមិនអាចចៀសផុតទេសម្រាប់ការងារក្នុងភាពជាដៃគូយូរអង្វែង។ ប៉ុន្តែ ការចរចាទាំងនោះ គួរគប្បីធ្វើឡើងដោយត្រឹមត្រូវ ស្មោះត្រង់ តម្លាភាព និងគ្មានការរើសអើង។

គ្មានកិច្ចសន្យាណាមួយដែលមានភាពបត់បែនគ្រប់គ្រាន់ និងមានសុពលភាពគ្រប់កាលៈទេសៈនោះឡើយ។ ជាងនេះទៅទៀត កិច្ចសន្យាលម្អិតពេកដែលមានគោលបំណងគ្របដណ្តប់គ្រប់ទិដ្ឋភាព នៃភាពជាដៃគូយូរអង្វែង អាចអនុវត្តមិនបានក្នុងពេលជាក់ស្តែងដែលតម្រូវឲ្យមានភាពបត់បែនក្នុងពេលប្រតិបត្តិការ។ ដូចគ្នានេះដែរ ការរៀបចំលម្អិតពេកធ្វើឲ្យគូភាគីក្នុងកិច្ចសន្យាព្យាយាម "ស្វែងរកចន្លោះប្រហោង" ជាជាងការធ្វើឲ្យការងារជាដៃគូដំណើរការទៅរលូន។ ដូច្នេះ ការចរចា ឬការកែសម្រួលលក្ខខណ្ឌ នៃកិច្ចសន្យាឡើងវិញនឹងមានភាពចាំបាច់ក្នុងពេលណាមួយនៅក្នុងភាពជាដៃគូយូរអង្វែង ដូចជា គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទជាដើម។ មធ្យោបាយដ៏ល្អបំផុតក្នុងការធ្វើឲ្យការអនុវត្តកិច្ចសន្យាមានតុល្យភាពដោយមានភាពបត់បែនចាំបាច់ អាចជាការរួមបញ្ចូលលក្ខខណ្ឌ នៃកិច្ចសន្យាដែលបញ្ជាក់ឲ្យច្បាស់ថា កាលៈទេសៈណាខ្លះដែលចាំបាច់ត្រូវតែពិចារណាកែសម្រួលឡើងវិញនូវឯកសារកិច្ចព្រមព្រៀងដើមនេះ។ គណៈកម្មការមួយចំនួនដូចជា គណៈកម្មការត្រួតពិនិត្យអចិន្ត្រៃយ៍ និងសកម្ម គណៈកម្មការដោះស្រាយវិវាទ និងមជ្ឈត្តកម្ម ជាដើមអាចនឹងបង្កើត និងចែងក្នុងលក្ខខណ្ឌ នៃកិច្ចសន្យា ព្រមទាំងអនុវត្តដើម្បីជួយពង្រឹងទំនាក់ទំនងរបស់គូភាគី។

ក្រសួងអភិវឌ្ឍន៍ជនបទនឹងចាត់វិធានការផ្លូវច្បាប់ចាំបាច់ ក្នុងការផ្លាស់ប្តូរលក្ខខណ្ឌមួយចំនួន ដើម្បីធ្វើឲ្យគម្រោង/កម្មវិធីហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទដែលកំពុងអនុវត្តនោះមានភាពរលូន។ ចំណុចនេះ ជាទូទៅ វាត្រូវបានគេទទួលស្គាល់ថា គឺជាផ្នែកមួយ នៃសិទ្ធរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំវិធាននានាដើម្បីបម្រើអត្ថប្រយោជន៍សាធារណជន ក៏ប៉ុន្តែ ដំណើរការនេះក៏ត្រូវតែធ្វើឡើងឲ្យមានតម្លាភាព និងមិនរើសអើងផងដែរ ព្រមទាំងមានការពិគ្រោះយោបល់ជាមួយភាគីដែលរងផលប៉ះពាល់ទាំងអស់ជាមុន។ ប្រសិនបើ លក្ខខណ្ឌក្នុងកិច្ចសន្យាក្លាយទៅជាឧបសគ្គក្នុងការបន្តភាពជាដៃគូនឹងគ្នា រហូតឈានដល់ការដកហូតទ្រព្យសកម្មរបស់វិនិយោគិន នោះគប្បីមានការទូទាត់សំណងជូនវិនិយោគិនឲ្យបានទាន់ពេលវេលា សមរម្យ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

### ៤.១០ គោលការណ៍ទី ១០៖ ប្រើប្រាស់យន្តការដោះស្រាយវិវាទដែលមានស្រាប់

យន្តការដោះស្រាយវិវាទដែលមានស្រាប់គួរគប្បីយកមកប្រើ ពេលណាមានវិវាទកើតឡើងនៅចំណុចពេលវេលាណាមួយ នៃគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ យើងអាចដោះស្រាយបានទាន់ពេលវេលា និងមិនលម្អៀង។

កិច្ចសន្យានេះរួមបញ្ចូលប្រការ/លក្ខខណ្ឌ និងយន្តការនានាដើម្បីកំណត់ពីបញ្ហាដែលអាចកើតមាននាពេលអនាគត (រួមទាំងការដោះស្រាយផលវិបាកដែលកើតចេញពីព័ត៌មានមិនគ្រប់គ្រាន់ផងដែរ) និងយន្តការដោះស្រាយវិវាទផ្លូវការ (ការធានាអនុវត្ត/លទ្ធផលការងារ ការត្រៀមបម្រុងជាយថាហេតុចំពោះការចរចាកិច្ចសន្យាឡើងវិញ ឧបាស្រ័យទៅមជ្ឈត្តកម្មអន្តរជាតិ)។ ជាងនេះទៅទៀត កិច្ចសន្យានឹងបញ្ជាក់ពីដំណោះស្រាយដែលមានសម្រាប់វិនិយោគិនឯកជន ក្នុងករណីមានវិវាទ។

វិវាទនឹងរំពឹងទុកថាមាន ហើយការដោះស្រាយដោយសន្តិវិធីនៅមជ្ឈត្តកម្ម គឺជាជម្រើសដ៏ប្រសើរ។ គេអាចជំរុញចំណុចនេះបន្ថែមបានតាមរយៈការបង្កើតគណៈកម្មការដោះស្រាយវិវាទកិច្ចសន្យា ដែលជួបប្រជុំនិងពិភាក្សាអំពីកិច្ចសន្យានោះយ៉ាងទៀងទាត់។ ការចាប់ផ្តើមកិច្ចពិភាក្សាឲ្យបានឆាប់នៅពេលដែលមានបញ្ហាប្រឈមកើតឡើង និងមុនពេលវិវាទរីករាលដាលទៅជាធំ គឺមានសារៈសំខាន់ណាស់។

### ៤.១១ គោលការណ៍ទី ១១៖ ជំរុញឲ្យការធ្វើធុរកិច្ចប្រកបដោយការទទួលខុសត្រូវ

វិស័យឯកជនដែលចូលរួមក្នុងការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ គួរគប្បីប្រតិបត្តិតាមគោលការណ៍ និងស្តង់ដាដែលបានព្រមព្រៀងសម្រាប់ការប្រតិបត្តិអាជីវកម្មប្រកបដោយការទទួលខុសត្រូវខ្ពស់។

បេសកកម្មស្នូល នៃធុរកិច្ច គឺដើម្បីកំណត់ និងគ្រប់គ្រងគម្រោង/កម្មវិធីវិនិយោគដែលផ្តល់លទ្ធផលប្រកួតប្រជែងដល់អ្នកផ្តល់មូលធន។ ដើម្បីបំពេញមុខងារស្នូលនេះ ការធ្វើធុរកិច្ចប្រកបដោយការទទួលខុសត្រូវរួមមានការអនុលោមតាមច្បាប់ជាធរមានទាំងអស់ ប៉ុន្តែ វាអាចលើសពីនេះទៅទៀត។ ការធ្វើធុរកិច្ចប្រកបដោយការទទួលខុសត្រូវក៏រួមមានការឆ្លើយតបទៅនឹងសេចក្តីរំពឹងទុករបស់សង្គម ដែលគេអាចទំនាក់ទំនងតាមរយៈមធ្យោបាយផ្សេងៗទៀតក្រៅពីច្បាប់ ជាពិសេស ក្នុងតំបន់ដែលមានអភិបាលកិច្ចមិនទាន់ប្រសើរ

ឡើង និងក្នុងតំបន់ផ្សេងៗទៀតដែលវិធានការច្បាប់ និងបទប្បញ្ញត្តិមិនទាន់ឆ្លុះបញ្ចាំងពីបំណងប្រាថ្នារបស់សាធារណជន។

ក្រសួងអភិវឌ្ឍន៍ជនបទគាំទ្រការប្រើប្រាស់គោលការណ៍ និងស្តង់ដា នៃការធ្វើធុរកិច្ចប្រកបដោយការទទួលខុសត្រូវ ដូចមានចែងនៅក្នុងលិខិតូបករណ៍របស់អង្គការ/ស្ថាប័នអន្តរជាតិ រាជរដ្ឋាភិបាល ដូចជា គោលការណ៍ណែនាំរបស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ (OECD) ស្តីពីសហគ្រាសអាជីវកម្មពហុជាតិសាសន៍ និងសេចក្តីប្រកាសត្រីភាគីរបស់អង្គការពលកម្មអន្តរជាតិ (ILO) ស្តីពីគោលការណ៍ដែលពាក់ព័ន្ធទៅនឹងសហគ្រាសអាជីវកម្មពហុជាតិសាសន៍ និងគោលនយោបាយសង្គម។ គោលការណ៍ណែនាំទាំងនេះរួមគ្នាចងក្រងជាបណ្តុំ នៃអនុសាសន៍ចំពោះសហគ្រាសអាជីវកម្មពហុជាតិសាសន៍ដែលទាក់ទងទៅនឹងក្រមសីលធម៌អាជីវកម្ម រួមទាំងទំនាក់ទំនងការងារ និងមុខរបរ ព្រមទាំងទំនាក់ទំនងវិជ្ជាជីវៈ សិទ្ធមនុស្ស បរិស្ថាន ការបញ្ចេញព័ត៌មាន ការប្រយុទ្ធប្រឆាំងនឹងអំពើស៊ីសំណូក ផលប្រយោជន៍អ្នកប្រើប្រាស់ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការប្រកួតប្រជែង និងពន្ធអាករ។ ខណៈពេលដែលគោលការណ៍ណែនាំនេះមិនមានចំណងផ្លូវច្បាប់សម្រាប់សហគ្រាសអាជីវកម្ម ក្រសួងអភិវឌ្ឍន៍ជនបទបានប្តេជ្ញាចិត្តជំរុញឲ្យមានការអនុវត្តគោលការណ៍ណែនាំទាំងអស់នេះក្នុងចំណោមសហគ្រាសអាជីវកម្មដែលកំពុងមានប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា និងជួយដល់ភាគីពាក់ព័ន្ធនៅក្នុង “ស្ថានភាព/ករណីជាក់លាក់” ណាមួយ ដោយជួយសម្របសម្រួលក្នុងការដោះស្រាយបញ្ហានានា។ គោលការណ៍ណែនាំទាំងនេះឆ្លុះបញ្ចាំងពីឧត្តមានុវត្តន៍សម្រាប់សហគ្រាសអាជីវកម្មទាំងអស់។

### ៤.១២ គោលការណ៍ទី ១២៖ យល់ដឹង និងទទួលខុសត្រូវសម្រាប់ផលវិបាកនានាដល់សង្គម

វិស័យឯកជនដែលចូលរួមក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទដល់សហគមន៍ចាំបាច់ត្រូវតែប្រុងប្រយ័ត្នអំពីផលវិបាកនានាដែលកើតចេញពីសកម្មភាពរបស់ខ្លួនចំពោះសហគមន៍។ វិស័យឯកជនត្រូវតែធ្វើការរួមគ្នាជាមួយអាជ្ញាធរសាធារណៈ ដើម្បីចៀសវាង និងកាត់បន្ថយផលប៉ះពាល់ទាំងឡាយដែលមិនអាចទទួលយកបានដោយសង្គម។ ដើម្បីឆ្លើយតបលើចំណុចនេះ ក្រសួងអភិវឌ្ឍន៍ជនបទនឹងអនុវត្តសកម្មភាពដូចខាងក្រោម៖

- ជំរុញការវាយតម្លៃ និងកិច្ចពិភាក្សាលើផលលំបាកនានាចំពោះអ្នកក្រីក្រកើតដែលចេញពីជម្រើសនៃបច្ចេកវិទ្យាផ្សេងៗ គោលការណ៍កំណត់តម្លៃ ផែនការវិនិយោគ។
- ធ្វើការជាមួយវិស័យឯកជនដើម្បីប្រើប័ណ្ណក្រីក្រ និងយល់ដឹងឲ្យកាន់តែប្រសើរអំពីតម្រូវការរបស់អ្នកក្រីក្រ។
- លើកកម្ពស់ការចូលរួមចំណែក ក្នុងការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការវាយតម្លៃផលប៉ះពាល់ពេញលេញលើបរិស្ថាន និងបន្តស្វែងរកការកែលម្អលទ្ធភាពក្នុងន័យការពារបរិស្ថាន។ ជំរុញការទទួលយក និងអនុវត្តគោលការណ៍គ្រប់គ្រងតម្រូវការទឹកជាមូលដ្ឋាន ដូចជា ការអភិរក្សទឹក ការដាក់ឲ្យប្រើប្រាស់ឧបករណ៍វាស់ស្ទង់ (សម្រាប់ប្រសិទ្ធភាព ការអភិរក្សទឹក និងផ្តល់អំណាចឲ្យអ្នកប្រើប្រាស់កាន់តែច្រើនជាងមុន) កាត់បន្ថយការលេចធ្លាយតាមរយៈការកែលម្អ ការជួសជុល

ការថែទាំ អនុវត្តវិធានការបច្ចេកទេសនានា និងកែច្នៃប្រើប្រាស់ទឹកឡើងវិញនៅពេលមានបញ្ហាខ្សត់ទឹក។

- លើកកម្ពស់ការអនុវត្តស្តង់ដាគ្រប់គ្រងបរិស្ថាន សម្រាប់សកម្មភាពផ្តល់សេវាកម្មដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធទឹកស្អាត និងប្រព័ន្ធទឹកកខ្វក់។
- ជំរុញការរាយការណ៍អំពីការអនុវត្ត/លទ្ធផលការងារផ្នែកសេដ្ឋកិច្ច បរិស្ថាន និងសង្គម។ លើកទឹកចិត្តឲ្យក្រុមហ៊ុនទាំងឡាយចូលរួមធ្វើការជាមួយអ្នកផ្តល់ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីត្រួតពិនិត្យតាមដានការសម្រេចចិត្ត និងសកម្មភាពរបស់ខ្លួនដែលអាចជះឥទ្ធិពលទៅលើបរិស្ថាន និងសង្គម។
- ជំរុញការរាយការណ៍អំពីការគោរពប្រតិបត្តិក្រមសីលធម៌យេនឌ័រ ឲ្យស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីសមភាពយេនឌ័រ។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នដល់អនុសញ្ញា C190 របស់អង្គការពលកម្មអន្តរជាតិ ឆ្នាំ ២០១៩ ស្តីពីអំពើហិង្សា និងការបៀតបៀនផ្លូវភេទ។ អនុសញ្ញានេះអនុវត្តបានគ្រប់វិស័យទាំងអស់ មិនថារដ្ឋ ឬឯកជន ទាំងវិស័យសេដ្ឋកិច្ចក្នុង និងក្រៅប្រព័ន្ធ ព្រមទាំងនៅតំបន់ទីក្រុង ឬជនបទ។

# ឯកសារយោង


- Organization for Economic Co-Operation and Development (2007). Principles for private sector participation in infrastructure.
- Organization for Economic Co-Operation and Development (2011). Guidelines for multinational enterprises.
- European Commission (2003). Guidelines for successful public-private partnerships.
- International Labour Organization (2022). Tripartite Declaration of Principles Concerning Multinational Enterprises and Social Policy.
- State Secretariat for Economic Affairs SECO Swiss Agency for Development and Cooperation Swiss Re (2005). Public-Private Partnerships for water supply and sanitation, policy principles, framework for sustainable partnerships.
- Tearfund and WaterAid (2003). Advocacy guide to private sector involvement in water services.